ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**

សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩

ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០

សាលក្រមលេខ ១៩ (ក)

ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ និងប្រកាសសាលក្រមនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ នៅសាលជម្រះក្តីនៃសាលាដំបូងខេត្តឧត្តរមានជ័យ។

សមាសភាពជំនុំជម្រះមានដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១១៩ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ ដែលមានគូវិវាទរវាង ៖

**ដើមចោទ៖** ឈ្មោះ [redacted] សុខវុទ្ធី តំណាងឱ្យដើមចោទក្រុមហ៊ុនភ្នំពេញផ្លាស្ទិច ប្រូដាក់ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted]

**មេធាវីតំណាងដោយអាណត្តិ** លោក [redacted] មានការិយាល័យនៅ [redacted]។

**ចុងចម្លើយ៖** ឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ២៣ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

### ១-អង្គហេតុនិងការអះអាងរបស់គូរភាគី

១.១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

១.១.១ រំលោយកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និង បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) មកដើមចោទ។

១.១.២ បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ ០១ % ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ឱ្យមកដើមចោទ គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

១.១.៣ បង្គាប់ឱ្យចុងចម្លើយសងប្រាក់ពិន័យស្មើនឹងពីរដងនៃចំនួន ១៨,៧៥៧.៦៥ ដុល្លាអាមេរិក (ដប់ប្រាំបីពាន់ប្រាំពីររយហាសិបប្រាំពីរដុល្លាអាមេរិក និងហុកសិបប្រាំសេន) ដែលមានទឹកប្រាក់សរុបចំនួន ៣៧,៥១៥.៣០ (សាមសិបប្រាំពីរពាន់ប្រាំរយដប់ប្រាំដុល្លាអាមេរិក និងសាមសិបសេន) ឱ្យមកដើមចោទ។

១.១.៤ បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាត និងសេវាមេធាវី ចំនួន ៤០,០០០,០០០រៀល (សែសិបលានរៀល)។

១.១.៥ ស្នើសុំឱ្យតុលាការចេញសាលក្រមដោយភ្ជាប់ជាមួយការប្រកាសអនុវត្តជាបណ្តោះអាសន្នគ្រង់កម្មវត្ថុនៃបណ្តឹងខាងលើ។

១.១.៦ បង្គាប់ឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

១.២-ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ ចុងចម្លើយបានទិញទុយោទឹកស្អាត (HDPE) ពីដើមចោទ ក្នុងតម្លៃ ១៩,១០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំបួនពាន់មួយរយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ហើយដើមចោទបានប្រគល់ទុយោទឹកស្អាត (HDPE) គ្រប់ចំនួនទៅឱ្យចុងចម្លើយរួចហើយ។ បន្ទាប់មកចុងចម្លើយបានសងប្រាក់ជាបន្តបន្ទាប់ ហើយនៅសល់ប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ដែលចុងចម្លើយមិនទាន់បានសងដើមចោទ។ ក្រោយមកចុងចម្លើយពុំអនុវត្តកាតព្វកិច្ចសងប្រាក់ ទើបភាគីដើមចោទ និងចុងចម្លើយ បានចុះកិច្ចសន្យាធានាសងប្រាក់ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ ដោយភាគីចុងចម្លើយធានាសងប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) មកភាគីដើមចោទ និងករណីមិនព្រមសងប្រាក់តាមការកំណត់នោះទេ ភាគីចុងចម្លើយយល់ព្រមចូលខ្លួនមកដោះស្រាយតាមនីតិវិធីច្បាប់ ប៉ុន្តែនៅតែចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចសងប្រាក់តាមកិច្ចសន្យា។ រហូតដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ដើមចោទ និង ចុងចម្លើយ បានចុះកិច្ចសន្យាដោយបានកំណត់ថាចុងចម្លើយត្រូវសងបំណុលបង់ប្រាក់រំលោះប្រចាំខែនូវទឹកប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) រួមបញ្ចូលនឹងការប្រាក់ចំនួន ០១% ក្នុងមួយខែ ក្នុងរយៈពេល ០៩ខែ ដោយក្នុងមួយខែត្រូវបង់ចំនួន ២១៧២.០៩ ដុល្លាអាមេរិក (ពីរពាន់មួយ

រយចិតសិបពីរ និងប្រាំបួនសេនដុល្លាអាមេរិកគត់) ដោយមានភ្ជាប់ជាមួយតារាងទឹកប្រាក់សរុប និងថ្ងៃដែលត្រូវបង់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨។ ចាប់ពីថ្ងៃបង្កើតកិច្ចសន្យាចុងក្រោយនេះ ហើយនៅពេលដល់កាលកំណត់ត្រូវសងគឺ ដើមចោទបានទំនាក់ទំនងជាមួយចុងចម្លើយជាច្រើនសារ នៅតែចុងចម្លើយពុំព្រមសងប្រាក់តាមតារាងសងប្រាក់នោះទេ ដែលជាការបំពានកិច្ចសន្យា និងប៉ះពាល់ពាល់ផលប្រយោជន៍របស់ដើមចោទយ៉ាងធ្ងន់ធ្ងរ ទើបដើមចោទសម្រេចដាក់ពាក្យបណ្ដឹងមកតុលាការតែម្ដង។

១.៣. សេចក្ដីថ្លែងការណ៍របស់គូភាគី

ក.សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអណត្តិឱ្យដើមចោទ

លោក [redacted] ដុល្លា បានថ្លែងការណ៍ថា៖ ខ្ញុំបាទសូមរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដោយមូលហេតុថា កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ ចុងចម្លើយបានទិញរយោទឹកស្អាត (HDPE) ពីដើមចោទ ក្នុងតម្លៃ ១៩,១០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំបួនពាន់មួយរយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ដូចមានបញ្ជាក់ក្នុងវិក្កយបត្រចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨។ កូនក្ដីរបស់ខ្ញុំបាទបានប្រគល់បំពង់ទុយោទឹកស្អាត (HDPE) គ្រប់ចំនួនទៅឱ្យចុងចម្លើយរួចហើយ។ ចុងចម្លើយបានសងប្រាក់ជាបន្តបន្ទាប់ ហើយនៅសល់ប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ដែលចុងចម្លើយមិនទាន់បានសងមកកូនក្ដីខ្ញុំបាទ។ ក្រោយមកចុងចម្លើយពុំអនុវត្តកាតព្វកិច្ចសងប្រាក់ ទើបកូនក្ដីខ្ញុំបាទ និង ចុងចម្លើយ បានចុះកិច្ចសន្យាធានាសងប្រាក់ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ ដោយភាគីចុងចម្លើយធានាសងប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) មកឱ្យកូនក្ដីខ្ញុំបាទ និងករណីមិនព្រមសងប្រាក់តាមការកំណត់នោះទេ ភាគីចុងចម្លើយយល់ព្រមចូលខ្លួនមកដោះស្រាយតាមនីតិវិធីច្បាប់ នៅតែចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចសងប្រាក់តាមកិច្ចសន្យា។ រហូតដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ កូនក្ដីរបស់ខ្ញុំ និង ចុងចម្លើយបានចុះកិច្ចសន្យាត្រង់ប្រការ១ នៃកិច្ចសន្យាថា "ភាគី ខ ចុងចម្លើយ ស្នើសុំភាគី ក ដើមចោទ សងបំណុលបង់ប្រាក់រំលោះប្រចាំខែនូវទឹកប្រាក់ចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) រួមបញ្ចូលនឹងការប្រាក់ចំនួន ០១% ក្នុងមួយខែ ក្នុងរយៈពេល ០៩ខែ ដោយក្នុងមួយខែត្រូវបង់ ២១៧២.០៩ ដុល្លាអាមេរិក (ពីរពាន់មួយរយចិតសិបពីរ និង ប្រាំបួនសេនដុល្លាអាមេរិក) ដោយមានភ្ជាប់ជាមួយតារាងទឹកប្រាក់សរុប និងថ្ងៃដែលត្រូវបង់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨។ គិតចាប់ពីថ្ងៃបង្កើតកិច្ចសន្យាចុងក្រោយនេះ ហើយនៅពេលដល់កាលកំណត់ត្រូវសង គឺកូនក្ដីរបស់ខ្ញុំបានទំនាក់ទំនងជាច្រើនមួយចុងចម្លើយជាច្រើនសារ នៅតែចុងចម្លើយពុំព្រមសងប្រាក់តាមតារាងសងប្រាក់

នោះទេ ដែលជាការបំពានកិច្ចសន្យា និង ប៉ះពាល់ផលប្រយោជន៍របស់ដើមចោទយ៉ាងធ្ងន់ធ្ងរ។ ផ្អែកតាមប្រការ៦ នៃកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ថា ក្នុងករណីមានវិវាទកើតឡើងពីការមិនគោរពកិច្ចសន្យានេះ ភាគីទាំងពីរត្រូវជូនដំណឹងឱ្យមានការអនុវត្តកាតព្វកិច្ចនេះឡើងវិញ ទោះបីតាមទូរស័ព្ទ តាមសារអេឡិចត្រូនិច ឬ លិខិតផ្ទាល់ដៃក៏ដោយ។ ភាគីដែលបំពានត្រូវបំពេញកាតព្វកិច្ចឡើងវិញតាមការជូនដំណឹងនេះឱ្យបានក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ដែលត្រូវបំពេញកាតព្វកិច្ចនេះ។ ករណីការបំពាននៅតែកើតមានក្រោយពេលផុតកំណត់នៃការអនុវត្តខាងលើនេះ ត្រូវកំណត់ថាជាការបំពានដោយពេញលេញ។ ភាគីដែលរងគ្រោះមានសិទ្ធិឯកតោភាគីក្នុងការរំលាយកិច្ចសន្យានេះ ហើយភាគីបំពានត្រូវទទួលខុសត្រូវសងការខូចខាតដល់ជនរងគ្រោះតាមស្ថានភាពជាក់ស្តែង ប្រសិនបើទំហំនៃសំណងមិនមានចែងក្នុងកិច្ចសន្យានេះ។ ផ្អែកតាមខ្លឹមសារនៃកិច្ចសន្យានេះភាគីដើមចោទមានសិទ្ធរំលាយកិច្ចសន្យា ដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីចុងចម្លើយបានដោយពេញលេញ និងមានសិទ្ធមានសំណងនៃការខូចខាតផ្សេងៗទៀតផងដែរ។ មូលហេតុនៃការទាមទារត្រង់ចំណុចទី១ នៃពាក្យបណ្តឹងគឺ ចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចំនួន ១៧,២០៨.៨២ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ហើយចុងចម្លើយពិតជាបានខកខានសងប្រាក់គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ មកដល់បច្ចុប្បន្នពិតប្រាកដមែន ដោយផ្អែកលើកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និងមាត្រា ៥៥៥ កថាខណ្ឌទី១ (ករណីកិច្ចបង់ថ្លៃទិញ) នៃក្រមរដ្ឋប្បវេណី និងមានការទទួលស្គាល់ត្រង់ចំណុចនេះពីចុងចម្លើយផងដែរ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ មូលហេតុនៃការទាមទារត្រង់ចំណុចទី០២ នៃពាក្យបណ្តឹង គឺចុងចម្លើយពិតជានៅជំពាក់ការប្រាក់ចំនួន ០១% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៧,២០៨.៨២ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ដោយផ្អែកលើកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨, មាត្រា ៥៥៩ និងមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី និងប្រកាសស្តីពីអត្រាការប្រាក់ ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ និងមានការទទួលស្គាល់ត្រង់ចំណុចនេះពីចុងចម្លើយនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។ មូលហេតុនៃការទាមទារត្រង់ចំណុចទី៣ នៃពាក្យបណ្តឹង គឺយោងតាមប្រការ ៥ នៃកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ បានចែងថា ក្នុងករណីដែលមូលប្បទានប័ត្ររបស់ភាគី ខ មានបញ្ហាដោយមិនអាចដកប្រាក់បាន ឬភាគីមានការយឺតយ៉ាវក្នុងការប្រាក់លើពីមួយសប្តាហ៍ភាគី ខ ជានាសងប្រាក់គុណនឹងពីរចំនួនទឹកប្រាក់ដែលត្រូវបង់ក្នុងខែនីមួយៗ។ ហេតុដូច្នេះផ្អែកតាមទឹកប្រាក់សរុប និងថ្ងៃដែលត្រូវបង់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ចំនួនទឹក



Scanned with CamScanner

ប្រាក់ដែលចុងចម្លើយត្រូវបង់ក្នុងខែនីមួយៗ គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ មានចំនួន ១៨,៧៩៧.៦៥ ដុល្លាអាមេរិក (ដប់ប្រាំបីប្រាំពីររយហាសិបប្រាំពីរដុល្លាអាមេរិក និងហុកសិបប្រាំសេន) គុណនឹងពីរ ស្មើនឹងចំនួន ៣៧,៥១៥.៣០ (សាមសិបប្រាំពីរពាន់ប្រាំរយដប់ប្រាំដុល្លាអាមេរិក និងសាមសិបសេន) ដោយផ្អែកតាមប្រការ ៥ នៃកិច្ចសន្យាខាងលើ, តារាងទឹកប្រាក់សរុប និងថ្ងៃដែលត្រូវបង់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨, មាត្រ ៥៥៩ (ការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ច) និងមាត្រា ៤០៣ (ការកំណត់ជាមុននូវចំនួនសំណង)នៃក្រមរដ្ឋប្បវេណី។ មូលហេតុនៃការទាមទារត្រង់ចំណុចទី០៤ នៃពាក្យបណ្តឹងគឺ ផ្អែកតាមមាត្រា ៣៩៨ កថាខណ្ឌ១ បានចែងថា ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។ មូលហេតុនៃការទាមទារត្រង់ចំណុចទី៥ នៃពាក្យបណ្តឹងគឺ ផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា តុលាការអាចប្រកាសអនុវត្តជាបណ្តោះអាសន្នលើកម្មវត្ថុនៃបណ្តឹងបាន។ ម្យ៉ាងចុងចម្លើយបានទទួលស្គាល់លើប្រាក់ដើម និងការប្រាក់តាមការទាមទាររបស់កូនក្តីរបស់ខ្លួនបាទ។ មូលហេតុនៃការទាមទារត្រង់ចំណុចទី៦ នៃពាក្យបណ្តឹងគឺ ផ្អែកតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

ខ.សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] រិទ្ធី បានថ្លែងការណ៍ថា៖ ខ្លួនបាទទទួលស្គាល់ថា ខ្លួនបាទពិតជាបានជំពាក់ប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) និងការប្រាក់ចំនួន ០១% លើប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន។ ដោយឡែកចំពោះប្រាក់ពិន័យ និងសំណងជម្ងឺចិត្ត ខ្លួនបាទសូមបដិសេធលើការទាមទារ ពោលគឺ ខ្លួនបាទស្នើសុំឱ្យតុលាការពិចារណាតាមច្បាប់។

## ២.សំអាងហេតុ

២.១ ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] សុខវុទ្ធី តំណាងស្របច្បាប់ឱ្យ ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២.២ យោងតាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] រិទ្ធី បានទទួលស្គាល់ថា ខ្លួនពិតជាបានជំពាក់ប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែត

សិបបួនដុល្លាអាមេរិក) និងការប្រាក់ចំនួន ០១% លើប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន ពិតប្រាកដមែន។

២.៣ ផ្អែកតាមការថ្លែងការណ៍របស់សហចុងចម្លើយ និងសេចក្តីថ្លែងរបស់ដើមចោទ ឃើញថាមានភាពស៊ីសង្វាក់គ្នាទៅក្នុងអង្គហេតុ ក៏ដូចជាភស្តុតាងដែលគូរភាគីបានដាក់ជូនតុលាការ ដែលអាចបញ្ជាក់ថាចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) និងការប្រាក់ចំនួន ០១% លើប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន ពិតប្រាកដមែន។

២.៤ ផ្អែកតាមមាត្រា ៥៥៥ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាតាមកាលបរិច្ឆេទ និង ទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា។

២.៥ ផ្អែកតាមមាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី ចំពោះកាតព្វកិច្ចដែលត្រូវបានបង្កើតការប្រាក់ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេត្រូវគិតអត្រាការប្រាក់ចំនួន ៥% ក្នុងមួយឆ្នាំ និងបើយោងតាមប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ អត្រាការប្រាក់កំណត់ត្រឹមតែ១៨% ក្នុងមួយឆ្នាំ ប៉ុណ្ណោះ។

២.៦ យោងតាមប្រការ៥ នៃកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ បានកំណត់ថា ក្នុងករណីដែលមូលប្បទានប័ត្ររបស់ចុងចម្លើយ មានបញ្ហាដោយមិនអាចដកប្រាក់បាន ឬ មានការយឺតយ៉ាវក្នុងការបង់ប្រាក់លើសពីមួយសប្តាហ៍ ចុងចម្លើយជានាសងប្រាក់គុណនឹងពីរនៃចំនួនទឹកប្រាក់ដែលត្រូវបង់ក្នុងខែនីមួយៗ។ ហេតុដូច្នេះផ្អែកតាមទឹកប្រាក់សរុប និងថ្ងៃដែលត្រូវបង់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៨ ចំនួនទឹកប្រាក់ដែលចុងចម្លើយត្រូវបង់ក្នុងខែនីមួយៗ គិតចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ មានចំនួន ១៨,៧៥៧.៦៥ ដុល្លាអាមេរិក (ដប់ប្រាំបីពាន់ប្រាំពីររយហាសិបប្រាំពីរដុល្លាអាមេរិក និងហុកសិបប្រាំសេន) គុណនឹងពីរ ស្មើនឹងចំនួន ៣៧,៥១៥.៣០ (សាមសិបប្រាំពីរពាន់ប្រាំរយដប់ប្រាំដុល្លាអាមេរិក និង សាមសិបសេន) ដោយផ្អែកតាមប្រការ ៥ នៃកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និងតារាងបង់ប្រាក់ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និងផ្អែកតាមមាត្រា ៥៥៥ និងមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី។

២.៧ ផ្អែកតាមមាត្រា ៣៩៨ កថាខណ្ឌ១ ក្នុងករណីដែលចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ដើមចោទអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។

២.៨ ចុងចម្លើយមានចេតនាទុច្ចរិតក្នុងការគេចវេសមិនទទួលខុសត្រូវ លើកាតព្វកិច្ចរបស់ខ្លួនជាកូនបំណុល ដោយមិនទាន់បានសងប្រាក់ដើមដែលជំពាក់ និងការប្រាក់ ទៅដើមចោទឡើយរហូតមកដល់បច្ចុប្បន្ន។

២.៧ កាលដែលចុងចម្លើយគេចវេសពីការអនុវត្តកាតព្វកិច្ចរបស់ខ្លួននេះ បាននាំឱ្យប៉ះពាល់ និងធ្វើឱ្យខាតបង់ផលប្រយោជន៍របស់ដើមចោទយ៉ាងធ្ងន់ធ្ងរ។ គប្បីតុលាការពិចារណាលើការសម្រេចអំពីសំណងជម្ងឺចិត្តតាមទំហំនៃផលប្រយោជន៍ដែលបានខាតបង់ ជូនដើមចោទឱ្យបានសមរម្យ។

## ៣ សេចក្ដីសម្រេចបញ្ចប់

១- ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] សុខវុទ្ធី តំណាងស្របច្បាប់ឱ្យ ក្រុមហ៊ុនភ្នំពេញប្លាស្ទិច ប្រូដាក់ ដូចមាននៅក្នុងកម្មវត្ថុនៃពាក្យបណ្ដឹងចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២- រំលាយកិច្ចសន្យាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និង បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] រិទ្ធី អាយុ ៤៣ឆ្នាំ សងប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) មកដើមចោទ។

៣- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] រិទ្ធី អាយុ ៤៣ឆ្នាំ សងការប្រាក់ចំនួន ០១% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៧,២០៨.៨៤ ដុល្លាអាមេរិក (ដប់ប្រាំពីរពាន់ពីររយប្រាំបីក្បៀសប៉ែតសិបបួនដុល្លាអាមេរិក) ចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] រិទ្ធី អាយុ ៤៣ឆ្នាំ សងប្រាក់ពិន័យចំនួន ៣៧,៥១៥.៣០ (សាមសិបប្រាំពីរពាន់ប្រាំរយដប់ប្រាំដុល្លាអាមេរិក និងសាមសិបសេន) ឱ្យមកដើមចោទ។

៥- បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាត និងការខាតបង់ពេលវេលាចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) ឱ្យមកដើចោទ។

៦-ប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី០២ នៃសេចក្ដីសម្រេចខាងលើ។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។



Scanned with CamScanner

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ចំពោះមុខគូរភាគីៗ ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ៗ

ថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តឧត្តរមានជ័យ,ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

**ចៅក្រម**

**ហត្ថលេខា និង ត្រា** [redacted]

---

**បានឃើញ**

ថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ឧត្តរមានជ័យ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

**ចៅក្រម**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ឧត្តរមានជ័យ, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]